**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សុន្ទរកថាបិទវេទិកាកសិករថ្នាក់ជាតិលើកទី០២
# ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី
# ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

សណ្ឋាគារភ្នំពេញ ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១១

---------

- **ឯកឧត្តមទេសរដ្ឋមន្ត្រី**
- **ឯកឧត្តមរដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ និងសមាជិក សមាជិកាអង្គវេទិកា ជាទីមេត្រី**

១. ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីរីករាយ ដោយបានចូលរួមជាមួយនឹងឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុងពិធីបិទវេទិកាកសិករថ្នាក់ជាតិលើកទី០២ ក្រោមប្រធានបទ “ រួមគ្នាជួយកសិករខ្នាតតូចបន្សាំ ទៅនឹងបម្រែបម្រួលអាកាសធាតុ ដើម្បីនិរន្តរភាពជីវភាព ” ។ ខ្ញុំយល់ឃើញថារយៈពេលពីរថ្ងៃកន្លងទៅនេះ យើងទទួលបានលទ្ធផលជាច្រើន ដោយអង្គពិធីបានចែករំលែកព័ត៌មាន និងការពិភាក្សាយ៉ាងផុសផុល ហើយខ្ញុំក៏មានសេចក្តីរីករាយក្នុងការថ្លែងសុន្ទរកថាបិទនាពេលនេះ ។

២. ក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៏កសិកម្ម និងជនបទ និងក្នុងនាមសហសម្របសម្រួលរៀបចំអង្គវេទិកាកសិករថ្នាក់ជាតិលើកទី ០២ នេះ ជាមួយនឹងអង្គការការីតាស-កម្ពុជា និងបណ្តាអង្គការនានាមួយចំនួនទៀត ខ្ញុំសូមសំដែងនូវអំណរគុណចំពោះវត្តមានឯកឧត្តម លោកជំទាវ

លោក លោកស្រី ទាំងអស់ ដែលបានចំណាយពេលវេលាចូលរួមក្នុងអង្គវេទិកា និងរួមវិភាគទានចែករំលែកបទពិសោធន៏ក្នុងវេទិការយៈពេលពីរថ្ងៃនេះ ។

៣. ការបម្រែបម្រួលអាកាសធាតុក្នុងសកលលោក ត្រូវបានគេទទួលស្គាល់ជាទូទៅថា: គឺជាបញ្ហាមួយនៃបណ្តាបញ្ហាអភិវឌ្ឍ ពិសេសនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ ដូចជាប្រទេសកម្ពុជាយើងជាដើម ។ បច្ចុប្បន្នប្រធានបទ " **បម្រែបម្រួលអាកាសធាតុ** " នេះបានលេចឡើងជាកត្តាមួយ ពុំអាចមើលរំលងបាន នៅក្នុងរបៀបវារៈនៃការអភិវឌ្ឍជាតិ ក៏ដូចជានៅក្នុងកិច្ចការទំនាក់ទំនងអន្តរជាតិ ព្រោះថា ការប្រែប្រួលអាកាសធាតុ ពុំមែនជាបញ្ហាបរិស្ថានដាច់ដោយឡែក ឬជាបញ្ហាវិស័យណាមួយតែឯងនោះទេ តែវាជាបញ្ហាអភិវឌ្ឍ មានចរិតអន្តរវិស័យ និងពហុជំនាញពាក់ព័ន្ធនឹងតួនាទី-ភារកិច្ចគ្រប់ក្រសួង-ស្ថាប័ន ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលជាប្រធានកិត្តិយស នៃគណៈកម្មាធិការជាតិគ្រប់គ្រងការបម្រែបម្រួលអាកាសធាតុ មានការចង្អុលបង្ហាញយ៉ាងច្បាស់ពីបញ្ហានេះ ហើយក្នុងនាមជាភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការបម្រែបម្រួលអាកាសធាតុ និងពិធីសារក្យូតូ រាជរដ្ឋាភិបាលបានខិតខំយ៉ាងខ្លាំង ឆ្លើយតបទៅនឹងការបម្រែបម្រួលអាកាសធាតុ ក្នុងក្របខ័ណ្ឌគោលនយោបាយចតុកោណ ដំណាក់កាលទី០២ របស់រាជរដ្ឋាភិបាល ក៏ដូចជាក្នុងការអនុវត្តអនុសញ្ញា និងពិធីសារនេះ ។ កន្លងមក ក្រសួងបរិស្ថាន ក៏ដូចជាក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធនានា បានខិតខំធ្វើឱ្យសម្រេចនូវសមិទ្ធផលជាច្រើន ក្នុងការជំរុញសកម្មភាពអនុវត្តគម្រោងយន្តការអភិវឌ្ឍន៏ស្អាត ការអនុវត្តវិធានការបន្សាំទៅនឹងការបម្រែបម្រួលអាកាសធាតុ ជាពិសេសកម្មវិធីសកម្មភាពជាតិបន្សាំនឹង ការបម្រែបម្រួលអាកាសធាតុ ការកសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹង ស្តីពីការបម្រែបម្រួលអាកាសធាតុ ដល់សាធារណៈជនគ្រប់ស្រទាប់ ។ល។ ដើម្បីអនុវត្តអនុសាសន៏ដ៏ថ្លៃថ្លា របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានថ្លែងនៅក្នុងឱកាសបើកវេទិកាជាតិលើកទី ១ ស្តីពីបម្រែបម្រួលអាកាសធាតុ ដោយជំរុញការបញ្ជ្រាបការងារបម្រែបម្រួលអាកាសធាតុ ទៅក្នុងវិស័យពាក់ព័ន្ធ ជាពិសេសវិស័យកសិកម្ម ធនធានទឹក ព្រៃឈើ ឧស្សាហកម្ម ថាមពល សុខាភិបាល ។ល។ សំដៅធានាឱ្យបាននូវការអភិវឌ្ឍកសិកម្មប្រកបដោយចីរភាព កំណើនផលិតកម្មស្រូវ សន្តិសុខស្បៀង ការ

អភិវឌ្ឍវិស័យឧស្សាហកម្ម និងវិស័យថាមពលប្រកបដោយចីរភាព ការរក្សាសុខភាពប្រជាពលរដ្ឋ និងការកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលអាចទប់ទល់បាននឹងលក្ខខណ្ឌអាកាសធាតុប្រែប្រួល។

៤. ក្នុងរយៈពេលពីរថ្ងៃនៃអង្គវេទិកាកសិករថ្នាក់ជាតិលើកទី០២ យើងទាំងអស់គ្នាបានស្តាប់មតិយោបល់ពីកសិករដែលជាអ្នកបានជួបប្រទះផ្ទាល់ ទៅនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ និងមានបទពិសោធន៍ដោយផ្ទាល់នូវផលប៉ះពាល់ នៃការបប្រែបម្រួលអាកាសធាតុ ដែលបញ្ជាក់កាន់តែច្បាស់ថា ការបម្រែបម្រួលអាកាសធាតុពិតជាបាន និងកំពុងកើតឡើង បង្កនូវក្តីវិនាសអន្តរាយ និងមានផលប៉ះពាល់យ៉ាងពិតប្រាកដមកលើកសិកររបស់យើង ។ ផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ បានធ្វើឱ្យមានភាពងាយរងគ្រោះ ដល់ក្រុមកសិករទន់ខ្សោយ ដូចជាកសិករខ្នាតតូចឱ្យកាន់តែមានសភាពរងគ្រោះធ្ងន់ធ្ងរ ពីព្រោះជីវភាពរស់នៅរបស់ពួកគាត់ពឹងផ្អែកទាំងស្រុងទៅលើវិស័យកសិកម្ម។ នេះជាព័ត៌មានពិតដែលយើងទាំងអស់គ្នា បានឮពីមាត់កសិករដែលមកចូលរួមក្នុងវេទិកានេះ ដូច្នេះការលើកជាវិធានការនានា ដើម្បីចូលរួមទប់ស្កាត់ផលប៉ះពាល់ពីការបម្រែបម្រួលអាកាសធាតុ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ទាំងក្នុងពេលបច្ចុប្បន្ន និងក្នុងពេលអនាគត ហើយខ្ញុំសូមសំណូពរឱ្យក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម និងអង្គការពាក់ព័ន្ធនានាត្រូវរួមសហការគ្នាឱ្យបានល្អ ដើម្បីប្រយុទ្ធនឹងបញ្ហាប្រឈមនៃបម្រែបម្រួលអាកាសធាតុ ។

**ឯកឧត្តម លោកជំទាវ**

**លោក លោកស្រី អ្នកនាងកញ្ញា**

៥. ថ្វីត្បិតតែរាជរដ្ឋាភិបាលបានធ្វើការងារជាច្រើន លើបញ្ហាបម្រែបម្រួលអាកាសធាតុ តែយើងត្រូវហ៊ានទទួលស្គាល់ថា : កម្ពុជានៅមានបញ្ហាប្រឈមជាច្រើនទៀត ត្រូវដោះស្រាយពីបញ្ហាបម្រែបម្រួលអាកាសធាតុ ដូចជាការពង្រឹងសមត្ថភាពស្ថាប័ន ការរៀបចំច្បាប់ និងឯកសារគោលនយោបាយ និងផែនការសកម្មភាពឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ ការសិក្សាស្រាវជ្រាវ និងការអភិវឌ្ឍ ហើយសំខាន់ជាងនេះទៅទៀតនោះ គឺការកៀរគរធនធានថវិកា

ដើម្បីអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាពជាតិ បន្សាំនឹងការបម្រែបម្រួលអាកាសធាតុ ។ យើងចាំបាច់ត្រូវប្តេជ្ញាចិត្តខ្ពស់ និងប្រែក្លាយវិបត្តិនេះឱ្យទៅជាឱកាសមួយ ដើម្បីយើងរៀនសូត្រឱ្យប្រទេសយើងមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាពិសេសដំណោះស្រាយបញ្ហាប្រឈមនានា ដែលបង្កឡើងដោយបម្រែបម្រួលអាកាសធាតុ ទៅលើកសិករខ្នាតតូច ដែលយើងត្រូវប្រកាន់យកវិធានការមានការសម្របសម្រួលខ្ពស់យកមកអនុវត្ត និងចាំបាច់ត្រូវឱ្យមានការចូលរួមពីស្ថាប័ននៅគ្រប់កម្រិត និងពីភាគីពាក់ព័ន្ធនានា ។

៦. ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ ខ្ញុំសូមផ្តល់អនុសាសន៍មួយចំនួនជូនដល់អង្គវេទិកាកសិករថ្នាក់ជាតិលើកទី០២ នេះធ្វើការពិចារណា និងសិក្សា សម្រាប់អង្គវេទិកាថ្នាក់ជាតិ ឬថ្នាក់តំបន់លើកក្រោយៗទៀត ដូចខាងក្រោមនេះ :

*១.* ចំពោះកសិករៈ ការបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ គឺផ្តោតជាសំខាន់លើការផ្លាស់ប្តូរឥរិយាបថរបស់ខ្លួន ត្រូវធ្វើការផ្លាស់ប្តូរទម្លាប់ចាស់ដែលធ្លាប់អនុវត្តកន្លងមក និងព្រមទទួលយកនូវសមិទ្ធផលបង្កើតថ្មីៗ និងត្រូវមានទស្សនៈបើកចំហ ក្នុងការសាកល្បងនូវអ្វីដែលថ្មី ដែលយល់ឃើញថានឹងជួយលោក-អ្នកបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ ព្រមទាំងកសាងភាពស៊ាំរបស់លោក-អ្នក ឆ្លើយតបទៅនឹងបម្រែបម្រួលអាកាសធាតុ ហើយកាន់តែសំខាន់ទៅទៀតនោះ គឺការធ្វើការរួមគ្នាជាមួយកសិករដទៃទៀត ដើម្បីចែករំលែកបទពិសោធន៍ ។

*២.* ចំពោះក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល ដែលមានភារកិច្ចធ្វើសមាហរណកម្មការវិភាគនានា អំពីបម្រែបម្រួលអាកាសធាតុ ទៅក្នុងដំណើរការកសាងផែនការ និងជំរុញយុទ្ធសាស្ត្រកំណើន ដែលគ្មានផលប៉ះពាល់ដល់អាកាសធាតុ ត្រូវធ្វើសមាហរណកម្មការបន្សាំបម្រែបម្រួលអាកាសធាតុ ទៅក្នុងគម្រោងអភិវឌ្ឍនានា កៀរគរធនធានហិរញ្ញវត្ថុពីប្រភពជាតិ និងអន្តរជាតិ ដើម្បីវិនិយោគលើការបន្សាំនេះ ។ ត្រូវយកចិត្តទុកដាក់ឱ្យបានខ្ពស់ ចំពោះស្ថានភាពរងគ្រោះរបស់ស្ត្រីលើបញ្ហាបម្រែបម្រួលអាកាសធាតុ និងលើកកម្ពស់យេនឌ័រ និងភាពជាអ្នកដឹកនាំរបស់ស្ត្រី ក្នុងការរកដំណោះស្រាយដែលពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ។

*៣.* ចំពោះដៃគូអភិវឌ្ឍ ការគាំទ្រផ្នែកមូលនិធិដល់បម្រែបម្រួលអាកាសធាតុ មិនគប្បីជាជំនួយអភិវឌ្ឍដដែលៗនោះទេ ។ មូលនិធិនេះគប្បីជាមូលនិធិថ្មីសុទ្ធសាធ ហើយធានាថា

ការផ្តល់មូលនិធិមានប្រសិទ្ធភាព និងបានទៅដល់ដៃប្រជាជនដែលត្រូវការជំនួយជាទីបំផុត រាជរដ្ឋាភិបាលចាំបាច់ត្រូវទទួលបាននូវការវិនិយោគ និងធ្វើជាម្ចាស់នៃដំណើរការនេះ ។

*៤.* អង្គការដៃគូអភិវឌ្ឍ បានបំពេញមុខងារយ៉ាងសំខាន់ជាអ្នកផ្តល់សេវា បំពេញចំណុចខ្វះចន្លោះ និងបានទៅដល់សហគមន៍ ស្ថិតនៅតំបន់ឆ្ងាយដាច់ស្រយាលដែលខ្វះខាត និងគ្មានសេវាសាធារណៈ ។ ខណៈពេលដែលការខ្វះខាតនៅតែមានបន្ត អង្គការជាដៃគូនៅមានមុខងារដទៃទៀតដែលត្រូវបំពេញ ដូចជាផ្សារភ្ជាប់ព័ត៌មានពីប្រជាពលរដ្ឋនៅមូលដ្ឋាន ទៅកាន់អ្នករៀបចំគោលនយោបាយ ។

*៥.* វិស័យឯកជន ដែលទាក់ទងនឹងវិបត្តិធាតុអាកាស បង្ហាញឱ្យឃើញកាលនុវត្តភាពធុរកិច្ចដ៏ល្អប្រសើរ តាមរយៈការនាំមកនូវសមិទ្ធិកម្មថ្មីៗដែលនឹងជួយកសិករក្នុងការបន្សាំខ្លួនទៅនឹងការបម្រែបម្រួលធាតុអាកាស ក៏ដូចជាអនុញ្ញាតឱ្យវិស័យឯកជនពង្រីកអាជីវកម្មរបស់ខ្លួន។ ផ្តើមចេញពីទស្សនវិស័យរបស់កសិករ តម្រូវការពិតប្រាកដ និងតម្រូវការបន្ទាន់ចំពោះមុខ ដែលអាចជួយពួកគេក្នុងការបន្សាំខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ គឺបច្ចេកទេស/សមិទ្ធិកម្មថ្មីៗ ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងធនធានធម្មជាតិដែលបានអភិរក្ស។ តម្រូវការទាំងនេះអាចបំពេញបាន ប្រសិនបើយើងទាំងអស់គ្នាសហការ និងរួមគ្នាធ្វើសកម្មភាពជាក់ស្តែង ។

៧. ជាទីបញ្ចប់ ក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍកសិកម្ម និងជនបទ និងក្នុងនាមជាសហអ្នករៀបចំវេទិកាកសិករថ្នាក់ជាតិលើកទី០២ ខ្ញុំសូមសំដែងនូវអំណរគុណសារជាថ្មីម្តងទៀត ចំពោះការអញ្ជើញចូលរួមរបស់ឯកឧត្តម អស់លោក លោកស្រីនៅក្នុងវេទិកាកសិករថ្នាក់ជាតិលើកទី ០២ និងសូមអរគុណដល់ការផ្តល់ថវិការៀបចំវេទិកានេះ ពីបណ្តាអង្គការដៃគូអភិវឌ្ឍនានា មានដូចជាអង្គការការីតាស-កម្ពុជា អង្គការអុកស្វាម អង្គការឌីស៊ីអេ/ស៊ីអេ អង្គការអិនជីអូហ្វ៊ុម និងអង្គការស៊ីអរអ៊ែស ។

ខ្ញុំសូមជូនពរសេរីសួស្តីជូនឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោក លោកស្រី អ្នកនាងកញ្ញា ទទួលបាននូវពុទ្ធពរទាំង ០៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាត ។

ខ្ញុំសូមប្រកាសបិទវេទិកាកសិករថ្នាក់ជាតិលើកទី ០២ ចាប់ពីពេលនេះតទៅ ។

**សូមអរគុណ!**